*The Kingdom of God*

Copyright © 2012 by The Gospel Coalition

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.
All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# នគរព្រះ

លោក ស្ទេផាន អ៊ុំ Stephen Um

## មាតិកា

នគរព្រះចាក់ពុម្ព /បណ្ដាលឲ្យទេវសាស្រ្តមានរូបរាងឡើង....3
នគរព្រះចាក់ពុម្ព/ បណ្ដាលឲ្យអត្តសញ្ញាណរបស់គ្រីស្ទបរិស័ទមានរូបរាងឡើង....8
នគរព្រះចាក់ពុម្ព/បណ្ដាលឲ្យសហគមន៍មានសណ្ឋានរូបរាងឡើង....11
កំណត់ ....13

សព្វថ្ងៃនេះ អ្នកខ្លះមិនចង់ឲ្យមានអំណាចណាត្រួតត្រាលើពួកគេនោះទេ ពួកគេគ្រាន់តែចង់បានអំណាចជារបស់ខ្លួនប៉ុណ្ណោះ ពីព្រោះពួកគេជឿថា គ្មានអំណាចណាអាចមានសមត្ថភាពជួយរំដោះគេបានឡើយ។ ពួកគេយល់ឃើញថា អំណាចខាងក្រៅគឺជាការកៀបសង្កត់។ បើសិននេះជាការពិត នោះយើងងាយស្រួលនឹងជឿថា មនុស្សមិនត្រូវការអំណាចណាដែលនៅខាងក្រៅឬត្រួតត្រាលើពួកគេនោះឡើយ។

លោក ដន កូភិត Don Cupitt បានគាំទ្រទស្សនៈនេះ គឺលោកបានប្រកាសថា "សម័យដែលមនុស្សបង្កើតរឿងព្រេងដើម្បីនឹងគាំទ្រអស់អ្នកដែលមានអំណាចបានបញ្ចប់ហើយ"។[១]ការពិត អ្វីដែលលោក កូភិតបង្រៀនមានភាពផ្ទុយនឹងខ្លួនឯង ពីព្រោះគាត់អះអាងថា អ្វីដែលគាត់បង្រៀនគឺពិតប្រាកដនិងមានអំណាច។ មនុស្សសម័យទំនើបជឿថា ការមានជម្រើសច្រើនបានជួយអោយមានសេរីភាព ប៉ុន្តែវាគឺពិតជាបានបង្អាក់ទឹកចិត្តវិញ។[២] លោក រីឆាត បោកខាំ Richard Bauckham និយាយថា

> មនុស្សជាច្រើនជឿថា ការជឿងល់ព្រះគឺមិនស៊ីគ្នានឹងស្វ័យភាពរបស់មនុស្សជាតិនោះទេ.....ជារឿយៗគេបាននិយាយខុសថា ព្រះបានលុបបំបាត់សេរីភាពចោលជាជាងបានលើកស្ទួយវានៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ។ គេថាទ្រង់គឺជាអ្នកកាន់អំណាចផ្ដាច់ការនៅស្ថានសួគ៌ដែលជាគំរូដល់របបកៀបសង្កត់នានានៅលើផែនដី ហើយបានប្រទានអំណាចដល់ពួកគេ។ នេះពិតជាមិនមែនជាលក្ខណរបស់ព្រះតាមព្រះគម្ពីរនោះឡើយ។ អំណាចរបស់ទ្រង់រំដោះយើងឲ្យរួចពីអំណាចរបស់មនុស្ស។ នេះព្រោះតែព្រះមិនបំពេញសម្រេចអំណាចរបស់ទ្រង់ដោយគ្របសង្កត់នោះទេ ប៉ុន្តែដោយការបម្រើដូចជាអ្នកបម្រើវិញ (ភីលីព ២:៦-១១)។[៣]

តើសេចក្ដីជំនឿគ្រីស្ទបរិស័ទយល់ថា អំណាច និងភាពជាស្ដេចគឺជាអ្វី? សាររបស់ព្រះគម្ពីរមិនលើកទឹកចិត្តឲ្យយើងធ្វើជាម្ចាស់លើខ្លួនឯងនោះទេ ប៉ុន្តែលើកស្ទួយអំណាចនៃព្រះគុណវិញ។ អំណាចដំបូងជារបស់ព្រះ ហើយអំណោយទានប្រកបដោយព្រះគុណគឺជាអង្គទ្រង់ផ្ទាល់។[៤] និយាយក្នុងពាក្យផ្សេង ការកើនឡើងនៃភាពជិតស្និទ្ធរវាងមនុស្សក្នុងទំនាក់ទំនងមួយនឹងកាត់បន្ថយកំរិតភាពឯករាជ្យរបស់ពួកគេជាមិនខាន។

ព្រះគម្ពីរបង្រៀនសេចក្តីពិតអំពីអំណាចរបស់ព្រះ អំណាចនៃព្រះបន្ទូលទ្រង់ និងអំណាចនៃសេចក្តីពិតដែលទ្រង់បានបើកសំដែង។ ដូច្នេះ ផ្ទៃរឿងអំពីភាពជាស្តេចរបស់ព្រះគឺជាបុព្វហេតុចំបងក្នុងបទគម្ពីរទាំងអស់។ ជំពូកនេះនឹងពិនិត្យមើលលើទេវ សាស្ត្រមួយ អត្តសញ្ញាណមួយ និងសហគមន៍មួយដែលនគរនេះបានបង្កើតឡើង។

## *នគរព្រះចាក់ពុម្ព/បណ្តាលឲ្យទេវសាស្ត្រមានរូបរាងឡើង*

នគរព្រះគឺជាសេចក្តីបង្រៀនសំខាន់មានក្នុងគ្រប់ទាំងបទគម្ពីរទាំងអស់។ ព្រះគម្ពីរក៏ហៅនគរព្រះថា "នគរស្ថានសួគ៌" "នគររបស់ព្រះគ្រីស្ទ" "នគររបស់ព្រះអម្ចាស់" និង "នគរ"។ ដោយសារព្រះគម្ពីរគឺជាសៀវភៅមួយ នោះមានអ្នកធ្វើអត្ថាធិប្បាយជាច្រើនបានប៉ុនប៉ងស្វែងរកផ្ទៃរឿងតាមព្រះគម្ពីរដែលរួបរួមមួយហើយភ្ជាប់សញ្ញា (ព្រះគម្ពីរសញ្ញាចាស់និងថ្មី) ទាំងពីរជាមួយគ្នា។ ពិតជាមានផ្ទៃរឿងសំខាន់ៗតាមព្រះគម្ពីរជាច្រើន ប៉ុន្តែយើងអាចគាំទ្រទស្សនៈដែលថា "ចំណងដែលចង(សញ្ញា) ទាំងពីរជាមួយគ្នាគឺជាការគ្រប់គ្រងរបស់ព្រះ"។[៥]

ក្នុងការកាត់ស្រាយព្រះគម្ពីរមានការពន្យល់ជាច្រើនលើពាក្យ "នគរ"។ អ្នកខ្លះបានកាត់បន្ថយនគរព្រះមកត្រឹមបទពិសោធន៍បច្ចុប្បន្នរបស់យើង ហើយអំណាចខាងក្នុងរបស់ព្រះវិញ្ញាណដែលធ្វើការក្នុងចិត្តរបស់មនុស្ស តែអ្នកផ្សេងទៀតក៏បានបង្រៀនថា នគរសំដៅទៅលើការបង្កបង្កើតខាងវិញ្ញាណ ខាងស្ថានសួគ៌ថ្មីនៅពេលអនាគត ឬនគរនោះស្មើនឹងពួកជំនុំដែលមើលឃើញ។

អ្នកផ្សេងៗទៀតបានកាត់បន្ថយនគរដោយការយល់ថាវាជាកម្មវិធីសង្គមដ៏ប្រសើរសម្រាប់អារ្យធម៌របស់មនុស្សដែលមិនសំដៅលើសេចក្តីប្រោសលោះរបស់បុគ្គលម្នាក់ៗនោះទេ។ ដូច្នេះ យោងតាមទ្រឹស្តីនេះ "ការសាងសង់" នគរ មានន័យថា ការបំបាត់បញ្ហាសង្គមទាំងអស់ដូចជា ភាពក្រីក្រ អយុត្តិធម៌សង្គម និងភាពមិនស្មើគ្នា។

ពេញក្នុងប្រវត្តិសាស្ត្រមានភាពខុសគ្នាក្នុងការកាត់ស្រាយ ពីព្រោះសេចក្តីបង្រៀនតាមព្រះគម្ពីរមានការផ្តោតខុសៗគ្នាជាច្រើន យើងមាននគរបច្ចុប្បន្ន (ម៉ាថាយ ១២:២៨, ២១:៣១ ម៉ាកុស ១០:១៥) ប៉ុន្តែនគរជាព្រះពរនាពេលអនាគតផងដែរ (១កូរិនថូស ១៥:៥០ ម៉ាថាយ ៨:១១ លូកា ១២:៣២) ជាព្រះពរសង្គ្រោះខាងវិញ្ញាណ (រ៉ូម ១៤:១៧ យ៉ូហាន ៣:៣) និងការគ្រប់គ្រងសង្គមនាពេលអនាគត (វិវរណៈ ១១:១៥)។

គន្លឹះក្នុងការដោះស្រាយការផ្តោតខុសៗគ្នាគឺជាការយល់អំពីអត្ថន័យដែលព្រះគម្ពីរផ្តល់ដល់ពាក្យ "នគរ"។ តើនគរព្រះគឺជាអ្វី? វចនានុក្រមសម័យទំនើបនឹងផ្តល់អត្ថន័យដល់ពាក្យនេះជា "តំបន់" "អាណាចក្រ" ឬ "កន្លែង"។ ការពន្យល់នេះបាននែនាំពួកអ្នកកាត់ស្រាយឲ្យឆ្ងាយពីការយល់ដឹងតាមព្រះគម្ពីរដែលផ្តោតលើ ឋានៈ ការគ្រប់គ្រង ការសោយរាជ្យ អំណាច និងអំណាចជាស្តេចរបស់ព្រះ។[៦]

រឿងប្រៀបប្រដូចរបស់ព្រះយេស៊ូវនៅក្នុងលូកាជំពូក១៩បញ្ជាក់ច្បាស់អំពីអត្ថន័យគ្រឹះរបស់នគរព្រះ។ រឿងនេះពណ៌នាអំពីបុរសត្រកូលខ្ពស់ម្នាក់ដែល "បានចេញទៅឯស្រុកឆ្ងាយដើម្បីគ្រងរាជ្យ រួចត្រឡប់មកវិញ" (លូកា ១៩:១២)។[៧] បុរសនេះមិនបានទៅប្រទេសផ្សេងទៀតដើម្បីបានគ្រប់គ្រងអាណាចក្រនោះទេ ប៉ុន្តែគាត់បានចាកចេញពីកន្លែងផ្ទាល់ខ្លួនទៅកន្លែងផ្សេងដើម្បីទទួលបានអំណាច ភាពជាស្តេច និងសិទ្ធិគ្រប់គ្រងតំបន់ដែលគាត់ត្រឡប់មកវិញ (លូកា ១៩:១៥)។ (ព្រះយេស៊ូវអាចកំពុងនិយាយអំពីស្តេចហេរ៉ូឌ ដែលបានចាកចេញទៅក្រុងរ៉ូមប្រយោជន៍ដើម្បីឲ្យស្តេចសេសារតែងតាំងគាត់ធ្វើជាស្តេចហើយគាត់អាចត្រឡប់មកស្រុកយូដាវិញសោយរាជ្យជាស្តេចហេរ៉ូឌ)។

ដំណាក់កាលខុសៗគ្នារបស់ប្រវត្តិសាស្ត្រប្រោសលោះបានបញ្ជាក់អំពីនគរព្រះគឺជាការគ្រប់គ្រងប្រកបដោយអធិបតីភាពរបស់ព្រះ។ សេចក្តីពិតតាមព្រះគម្ពីរនេះបំបែកចេញពីសេចក្តីពិតដែលថា ព្រះដែលជាអង្គគ្រប់គ្រងមានព្រះជន្មរស់អស់កល្បពិត តែងតែសោយរាជ្យលើស្នាព្រះហស្តរបស់ទ្រង់ជានិច្ច។ "នគរព្រះមានក្នុងបច្ចុប្បន្ននេះតែយើងមិនទាន់បាន

ស្គាល់ពេញលេញនៅឡើយ គឺជាការអនុវត្តអធិបតីភាពរបស់ព្រះនៅក្នុងលោកិយដោយយល់ដល់សេចក្ដីប្រោសលោះចុងក្រោយរបស់ស្នាព្រះហស្តទាំងអស់”។[៨]

## ការគ្រប់គ្រងរបស់ព្រះលើស្នាព្រះហស្ត

នៅពេលយើងពិភាក្សាអំពីភាពជាស្ដេចរបស់ព្រះ មានមនុស្សជាច្រើនមិនបានផ្ដោតឲ្យបានគ្រប់គ្រាន់លើការគ្រប់គ្រងពិភពលោករបស់ព្រះក្នុងនាមជាព្រះអាទិករនៃពិភពលោកនោះទេ (ទំនុកដំកើង ២៤:១, ៤៧:១-៩, ៨៣:១៨, ៩៣:១, ៩៥:៣-៧, ១០៣:១៩, ១១៣:៥ ដានីយ៉ែល ៤:២៥-២៦, ៥:២១ ម៉ាថាយ ៥:៣៤ អេភេសូរ ១:២០ កូល៉ុស ១:១៦ ហេព្រើរ ១២:២ វិវរណៈ ៧:១៥)។ មានទំនាក់ទំនងច្បាស់លាស់មួយរវាងការសោយរាជ្យរបស់ព្រះយ៉ាវេនិងប្រវត្តិសាស្ត្ររជ្ជកាលរបស់ជនជាតិអ៊ីស្រាអែល (១សាំយ៉ូអែល ៨) ប៉ុន្តែការគ្រប់គ្រងជាស្ដេចរបស់ព្រះបានចាប់ផ្ដើមដោយអធិបតីភាពរបស់ព្រះនិងការថែរក្សាសណ្ដាប់ធ្នាប់របស់ពិភពលោកដែលទ្រង់បានបង្កើតមក។ លោក ហ្គោលវឺសឌី Goldsworthy និយាយថា

> ការគ្រប់គ្រងប្រកបដោយអធិបតីភាពរបស់ព្រះបានសំដែងយ៉ាងច្បាស់នៅក្នុងសួនច្បារអេដែននៅពេលព្រះអង្គបានដាក់ព្រំដែនដើម្បីសាកល្បងមើល តើអ័ដាមនឹងស្ដាប់បង្គាប់ឬទេ (លោកុប្បត្តិ ២:១៥-១៧)។ ព្រះពរនៃនគរព្រះមានទាំងក្នុងទំនាក់ទំនងរបស់មនុស្សជាមួយព្រះ និងទំនាក់ទំនងរបស់មនុស្សជាមួយរបស់សព្វសារពើ។ ធម្មជាតិបានចុះចូលចំពោះអំណាចមនុស្ស ហើយចំរើនឡើងដើម្បីបំពេញសេចក្ដីត្រូវការរបស់មនុស្ស។[៩]

ព្រះជាម្ចាស់ទ្រង់បានគ្រប់គ្រងដោយតែងតាំងមនុស្សជារាជានុសិទ្ធ “កាតព្វកិច្ចដែលព្រះប្រទានឲ្យមនុស្សគ្រប់គ្រងលើលោកិយដែលមានស្ថានភាពដូចជាសួនច្បារអេដែន (លោកុប្បត្តិ ១:២៨) ដែលយើងអាចមើលឃើញជាទំនាក់ទំនាក់សម្ពន្ធមេត្រីរវាងព្រះនឹងមនុស្ស”។[១០]

យើងមើលឃើញផ្ទៃរឿងអំពីនគរព្រះពេញក្នុងកំឡុងពេលប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរ។ សេចក្ដីពិតថាព្រះជាស្ដេចគឺជាគ្រឹះសម្រាប់មនុស្សធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយដែលបានស្គាល់ព្រះរបស់ពួកគេគឺជាស្ដេចគ្រប់គ្រងប្រកបដោយអធិបតីភាព។ ទ្រង់បានគង់នៅជាមួយពួកគេនៅពេលពួកគេបានធ្វើដំណើរ ហើយបានការពារនិងប្រទានជម្រកនៅពេលពួកគេកំពុងបង្កើតពូជពង្សដែលនឹងត្រូវធ្វើជារាស្ត្រជ្រើសតាំងពិសេសរបស់ទ្រង់។

ការផ្ដោតលើការសោយរាជ្យរបស់ព្រះ គឺជាដំបូងលើកូនចៅរបស់អ័ប្រាហាំនិងទឹកដីរបស់អ៊ីស្រាអែល។[១១] លោកុប្បត្តិ ៤-១១ ពិពណ៌នាអំពីឮយុកោរបស់អ័ប្រាហាំ។ព្រះអង្គបានសន្យាដល់អ័ប្រាហាំថា គាត់នឹងក្លាយជាជាតិសាសន៍ដ៏ធំ គេនឹងទទួលទឹកដីដ៏ធំ និងមានទំនាក់ទំនងពិសេសជាមួយព្រះអង្គ (លោកុប្បត្តិ ១២:១-៣)។ អ្នកខ្លះបានកាត់ស្រាយសេចក្ដីសន្យាទាំងបីនេះជាការសង្កត់ធ្ងន់លើការពិពណ៌នាតាមព្រះគម្ពីរអំពីនគរព្រះដែលមានរាស្ត្ររបស់ព្រះ អាណាចក្ររបស់ព្រះ និងការគ្រប់គ្រងរបស់ព្រះ។[១២]

## ការគ្រប់គ្រងរបស់ព្រះក្នុងការរំដោះចេញពីការគ្រប់គ្រងរបស់ស្រុកអេស៊ីព្ទ

នៅពេលចាកចេញពីអេស៊ីព្ទ ព្រះបានបង្កើតរាជ្យរបស់ទ្រង់លើអ៊ីស្រាអែលតាមរយៈការធ្វើអន្តរាគមន៍ និងសកម្មភាពសង្គ្រោះដ៏មានអំណាចព្រះចេស្ដាជាបន្តបន្ទាប់ (ឧទាហរណ៍សូមមើល និក្ខមនំ ១៥ ចោទិយកថា ៦:២០-២៤, ២៦:៥-១០ យ៉ូស្វេ ២៤:៥-១៣ ទំនុកដំកើង ៧៨, ១០៥, ១០៦, ១១៤, ១៣៥, ១៣៦ និងនេហេមា ៩:៩-១៥)។ ការរំដោះមនុស្សចេញពីទាសភាពការអស្ចារ្យនៃគ្រោះកាចនិងការញែកទឹកសមុទ្រ ការថែរក្សាជនជាតិអ៊ីស្រាអែលនៅក្នុងទីរហោស្ថាន និងការបើកសំដែងអង្គទ្រង់ដល់រាស្ត្ររបស់ព្រះអង្គ។ មនុស្សបានមើលឃើញអធិបតីភាពរបស់ព្រះយ៉ាវេតាមរយៈសកម្មភាពសង្គ្រោះរបស់ទ្រង់ “ការបង្កើតប្រវត្តិសាស្ត្រមួយដែលមានព្រះគ្រប់គ្រង ហើយប្រវត្តិសាស្ត្រនេះធ្វើដំណើរឆ្ពោះទៅកាន់អនាគតមួយដែលស្របតាមបំណងព្រះហឫទ័យទ្រង់”។[១៣] ព្រះបានសំដែងការគ្រប់គ្រងរបស់ទ្រង់នៅពេលព្រះអង្គបាន

រំដោះរាស្ត្ររបស់ទ្រង់ចេញពីកណ្តាប់ដៃរបស់ស្តេចផារ៉ោន ហើយបាននាំពួកគេចូលទៅក្នុងទឹកដីសន្យា (និក្ខមនំ ១៥, ១៩:៥-៦)។

## ការគ្រប់គ្រងរបស់ព្រះក្នុងកំឡុងរជ្ជកាលនិងពួកហោរា

ប្រវត្តិសាស្ត្រនៃសេចក្តីសង្គ្រោះក្នុងកំឡុងរជ្ជកាលគឺមានពេញដោយសោកនាដកម្ម។ ព្រះបានត្រាស់ហៅអ៊ីស្រាអែលឲ្យញែកជាបរិសុទ្ធ ធ្វើជាទីបញ្ចេញពរដល់លោកិយ និងធ្វើជាអនុភ្នាក់ងាររបស់ព្រះដើម្បីត្រួតត្រាទឹកដី (១របាក្សត្រ ២៩:២៣, ២របាក្សត្រ ៦) ប៉ុន្តែគួរឲ្យសោកស្តាយដែលយើងបានឃើញប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលមានពេញដោយភាពមិនស្មោះត្រង់ច្រើនជាងភាពស្មោះត្រង់ មានការថ្វាយបង្គំរូបព្រះច្រើនជាងការថ្វាយបង្គំព្រះយ៉ាវេ និងមានការបះបោរច្រើនជាងការស្តាប់បង្គាប់ទៅវិញ។ ពួកពលបរិវារនៅស្ថានសួគ៌តែងតែបានថ្វាយបង្គំនិងសរសើរតម្កើងសេចក្តីបរិសុទ្ធរបស់ព្រះដោយ "ការបម្រើដែលស្ម័គ្រចិត្ត"[១៤] ប៉ុន្តែមនុស្សបានបដិសេធការគោរពព្រះជាស្តេច ដែលនេះពន្យល់អំពីការលេចឡើងនគរលើផែនដីដែលពេញដោយការទាស់ប្រឆាំងនឹងព្រះ។ ដូច្នេះ កណ្ឌគម្ពីរហោរានៃនាំអំពីព្រះរាជសារនៃសេចក្តីសង្ឃឹមដែលនឹងបានបំពេញសម្រេចដោយព្រះមែស៊ី ដែល "នឹងវិនិច្ឆ័យមនុស្សអាក្រក់ ហើយនាំមនុស្សដែលបានប្រោសលោះចូលទៅក្នុងការបង្កបង្កើតថ្មី (អេសេគាល ៣៦, ៤៧ អេសាយ ៣៥, ៥៥, ៦៥ សាការី ១៤)"។[១៥]

ថ្ងៃដ៏ធំនិងពេញដោយសិរីល្អនាពេលអនាគតនេះនៅពេលគ្រប់ទាំងអស់នឹងត្រូវបានស្តារឡើងវិញ និងជាសម័យក្នុងប្រវត្តិសាស្ត្រប្រោសលោះដែលការគ្រប់គ្រងសកលលោករបស់ព្រះនឹងមកដល់ (អេសាយ ២៦:១-១៥, ២៨:៥-៦, ៣៣:៥-២៤, ១៧-២២, ៤៤:៥ អេសេគាល ១១:១៧-២១, ២០:៣៣-៣៨, ហូសេ ២:១៦-១៧ សាការី ៨:១-៨) ជាមួយនឹងសេចក្តីសុចរិតរបស់នគរ (អេសាយ ១១:៣-៥, យេរេមា ២៣:៥-៦) សន្តិភាពនិងការស្រុះស្រួលគ្នាដ៏នៅអស់កល្បជានិច្ច (អេសាយ ២:២-៣, ៩:៥-៦, ១១:៦-៧, ៣៥:៩ មីកា ៥:៤ សាការី ៩:៩-១០)។[១៦]

## ការគ្រប់គ្រងរបស់ព្រះតាមរយៈព្រះមែស៊ីក្នុងព្រះគម្ពីរសញ្ញាថ្មី

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ទាំងព្រះយេស៊ូវនិងយ៉ូហានបាទីស្ទបានប្រកាសថា នគរស្ថានសួគ៌ជិតដល់ហើយ (ម៉ាថាយ ៣:២, ៤:១៧ ម៉ាកុស ១:១៥) នគរនៅលើផែនដីបានមកតាមរយៈការយកនិស្ស័យជាមនុស្សនិងព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ (ម៉ាថាយ ២:២, ៤:២៣, ៩:៣៥, ២៧:១១ ម៉ាកុស ១៥:២ លូកា ១៦:១៦, ២៣:៣ យ៉ូហាន ១៨:៣៧)។ ថ្វីបើព័ន្ធកិច្ចនៅលើផែនដីនេះមានវត្តមានរួចទៅហើយ ក៏យើងមិនទាន់បានឃើញការបំពេញសម្រេចចុងក្រោយរហូតដល់ពេលព្រះគ្រីស្ទយាងត្រឡប់មកក្នុងសិរីល្អម្តងទៀតនោះទេ (១កូរិនថូស ១៥:៥០-៥៨, វិវរណៈ ១១:៥)។

បេសកកម្មសំខាន់នៃការនាំដំណាក់កាលចុងក្រោយរបស់នគរព្រះបានដំណើរការដើម្បីនាំមនុស្សចូលទៅក្នុងនគរព្រះវិញ (ម៉ាថាយ ៥:២០, ៧:២១ យ៉ូហាន ៣:៣)។ នគរដែលបានមកដល់លោកីយ៍ដែលជាការគ្រប់គ្រងដ៏មានអំណាចរបស់ព្រះ "បានកើតមកតាមរយៈផ្លូវថ្មីមួយ ពីព្រោះមានស្តេចអង្គទ្រង់ផ្ទាល់យាងមក "ប្រកាសសកម្មភាពប្រោសលោះដ៏ធំបំផុតរបស់ព្រះ ហើយសម្រេចសកម្មភាពនេះ"។[១៧] ព្រះយេស៊ូវបានបង្រៀនរឿងប្រៀបប្រដូចផ្សេងៗរបស់ទ្រង់ដើម្បីធ្វើជាឧទាហរណ៍ពន្យល់ដល់ពួកអ្នកដើរតាមរបស់ទ្រង់អំពីសេចក្តីពិតផ្សេងៗនៃនគររបស់ទ្រង់ (ម៉ាថាយ ១៣:១១)។ ថ្វីបើយើងបានទទួលគុណប្រយោជន៍និងឯកសិទ្ធិតាមរយៈដំណឹងល្អហើយ(អេភេសូរ ១:៣) ក៏ព្រះពរសិរីល្អនាពេលអនាគតត្រូវបានត្រៀមសម្រាប់អស់អ្នកដែលព្រះ បានសន្យានឹងប្រទានឲ្យ (ម៉ាថាយ ២៥:៣១, ៣៤)។[១៨]

ពេញក្នុងព្រះគម្ពីរសញ្ញាចាស់ មានរឿងជាច្រើន[១៩] ហើយមានតែព្រះគ្រីស្ទប៉ុណ្ណោះដែលមានសមត្ថភាពដោះស្រាយរឿងទាំងនេះព្រមទាំងបំពេញសម្រេចតាមការរំពឹងចង់បាន។ នោះគឺជាការគ្រប់គ្រងដែលសុចរិតឥតខ្ចោះមានសន្តិភាពនិងការសង្គ្រោះយ៉ាងពេញលេញ។ តាំងពីពេលមនុស្សបះបោរនៅក្នុងសួនច្បារអេដែនមក មនុស្សបានបាត់បង់សេរីភាពដើម្បីរីករាយជាមួយសិរីល្អនៃការគ្រប់គ្រងរបស់ព្រះ ដូច្នេះ ប្រវត្តិសាស្ត្រមនុស្សជាតិគឺជាការស្វែងរកស្តេចឥតខ្ចោះពិតប្រាកដ។

ការបរាជ័យរបស់អ៊ីស្រាអែលក្នុងការចុះចូលនឹងអំណាចរបស់ទ្រង់(ជាពិសេសក្នុងកំឡុងរជ្ជកាល)គឺជាសោកនាដកម្មរបស់ប្រវត្តិសាស្ត្រតាមព្រះគម្ពីរ។ ផ្ទុយពីការចុះចូលនិងការទុកចិត្តលើព្រះជាម្ចាស់នោះជនជាតិអ៊ីស្រាអែលបង្ហាញថាចិត្តរបស់មនុស្សនិយមថ្វាយបង្គំរូបព្រះវិញ។ ពួកអ្នកតំណាងរាស្ត្ររបស់ព្រះទាំងអស់ចាប់ពី អ័ដាម ណូអេ អ័ប្រាហាំ យ៉ាកុប ម៉ូសេ និងដាវីឌ និងពួកអ្នកដឹកនាំអស្ចារ្យដទៃៗទៀត បានបរាជ័យក្នុងការផ្តល់ការព្យាបាលការរំដោះចេញពីទាសភាពនិងការជាប់ចំណង។ ព្រះបានប្រទានដំណោះស្រាយតាមរយៈការយកនិស្ស័យជាមនុស្ស គឺព្រះអង្គទ្រង់ផ្ទាល់បានយាងមកឯមនុស្សជាតិ ហើយតាមរយៈការងាររងទុក្ខរបស់ព្រះមែស៊ីបានធ្វើឲ្យគ្រប់ទាំងអស់ត្រូវបានធ្វើជាថ្មីឡើងវិញ។ ព្រះបានធ្វើឲ្យអង្គទ្រង់ដូចនឹងពួកមនុស្សដែលព្រះបានបោះបង់ចោល។

បំណងព្រះហឫទ័យព្រះក្នុងការធ្វើឲ្យដូចជាពួកមនុស្សដែលព្រះបានបោះបង់ចោលនៅក្នុងការសុគតរបស់ទ្រង់ទាក់ទងនឹងអ្នកបម្រើដែលរងទុក្ខនៅក្នុងអេសាយ ៥២:១៣-៥៣:១២ ដែលអ្នកបម្រើនេះបានផ្ទុកអំពើបាបរបស់មនុស្សជាច្រើនហើយបានរងទុក្ខជំនួសយើង។

> នៅពេលគ្រីស្ទបរិស័ទអានអេសាយជំពូក៥២-៥៣ គេយល់ថាអត្ថបទនេះបានសរសេរអំពីព្រះគ្រីស្ទ ដែលជាព្រះហើយជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដែលបានទាំងរងទុក្ខដោយការបន្ទាបខ្លួននិងសុគតហើយក៏ត្រូវបានព្រះលើកតម្កើងឡើងផងដែរ។[២០]

សេចក្តីសង្ឃឹមថាមនុស្សបះបោរនឹងត្រូវបានប្រោសលោះហើយស្នាព្រះហស្តដែលបាក់បែកត្រូវបានបង្កើតជាថ្មីវិញ គឺត្រូវបានបំពេញសម្រេចនៅក្នុងព្រះយេស៊ូវគ្រីស្ទត្រឡប់ជាសាច់ឈាម។ នគរបានមកដល់តាមរយៈការយាងមកនិងសកម្មភាពរបស់ស្តេចជាព្រះមែស៊ី។ ព្រះយេស៊ូវដែលជារាស្ត្រពិតប្រាកដ វត្តមានពិតប្រាកដ និងអំណាចពិតប្រាកដរបស់ព្រះបានបំពេញសម្រេចការពិពណ៌នាតាមព្រះគម្ពីរអំពីនគររបស់ព្រះ គឺរាស្ត្ររបស់ព្រះ ទីកន្លែងរបស់ទ្រង់ និងអំណាចរបស់ទ្រង់។

ការបំពេញសម្រេចនូវរាស្ត្ររបស់ព្រះ(ព្រះគ្រីស្ទគឺជារាស្ត្ររបស់ព្រះ)។ លូកាពិពណ៌នាអ័ដាមជាកូនព្រះ (លូកា ៣:៣៨) តែនិក្ខមនំ ៤:២២ សំដៅលើអ៊ីស្រាអែលដែលជារាស្ត្ររបស់ព្រះជាកូនច្បងរបស់ព្រះ។ ព្រះយេស៊ូវ (ដែលជាអ័ដាមទីពីរឥតខ្ចោះ)ជាកូនព្រះ "ព្រះរាជបុត្រាស្ងួនភ្ងា" (លូកា ៣:២២) និងជាអ៊ីស្រាអែលពិតប្រាកដដែលបានសម្រេចបាននូវអ្វីដែលទាំងអ័ដាមទីមួយនិងអ៊ីស្រាអែលបានបរាជ័យធ្វើគឺទ្រង់បានចុះចូលចំពោះស្តេចនៃពិភពលោក។ "ដូច្នេះ រឿងអំពីការត្រូវសេចក្តីល្បួងរបស់ព្រះយេស៊ូវផ្ទុយពីជ័យជំនះរបស់សាតាំងលើអ័ដាមក្នុងសួនច្បារនិងលើអ៊ីស្រាអែលក្នុងទីរហោស្ថាន" ដូច្នេះហើយ "បទទំនាយទាំងអស់ដែលទាក់ទងនឹងការស្តារឡើងវិញរបស់អ៊ីស្រាអែលដែលជារាស្ត្ររបស់ព្រះត្រូវបានបំពេញសម្រេចនៅក្នុងព្រះយេស៊ូវ"។[២១]

ការបំពេញសម្រេចនូវព្រះវត្តមានព្រះ។ "រោងឧបោសថអាច...បង្ហាញអំពីព្រះយេស៊ូវជាព្រះបន្ទូលនិងសិរីល្អរបស់ព្រះក្នុងចំណោមមនុស្សជាតិ"។[២២] ម៉ូសេមិនអាចមើលឃើញសិរីល្អដែលសាយភាយរបស់ព្រះបានទេ (និក្ខមនំ ៣៣:២០) តែអស់អ្នកដែលជឿអាចមើលឃើញបាន (យ៉ូហាន ១:១៤) ពីព្រោះព្រះបន្ទូលត្រឡប់ជាសាច់ឈាមបានឃើញព្រះវិញ (យ៉ូហាន ១:១៨, ៣:១១)។

ដូច្នេះ ព្រះយេស៊ូវដែលជាការបើកសំដែងធំបំផុត អំពីកន្លែងគង់នៅរបស់ព្រះ មានព្រះបន្ទូលអំពីព្រះវិហារនៅក្នុងកណ្ឌដំណឹងល្អយ៉ូហាន។ ទ្រង់គឺជា "ព្រះវិហាររបស់ព្រះ(ដ៏ជាមនុស្ស)នៅលើផែនដីអស់កល្បជានិច្ច"[២៣] ដែលគង់ក្នុងចំណោមរាស្ត្ររបស់ទ្រង់ដែលធ្វើជានិមិត្តរូបនៃវត្តមានចុងក្រោយនៃព្រះវិហាររបស់ព្រះក្នុងសម័យរបស់ព្រះមែស៊ី។ យញ្ញបូជាចុងក្រោយនឹងត្រូវបានថ្វាយដល់ព្រះនៅក្នុង "ព្រះវិហារ"នេះ ដែលជារូបកាយរបស់ព្រះគ្រីស្ទ (យ៉ូហាន ២:១៩-២២) តែ

ព្រះយេស៊ូវមានបន្ទូលថា បន្ទាប់ពីបីថ្ងៃព្រះវិហារដ៏រស់ពិតនឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ដើម្បីជំនួសព្រះវិហារក្រុងយេរូសាឡឹម។[២៥]

នគរព្រះមិនអាចដាច់ចេញពីវត្តមានរបស់ព្រះយេស៊ូវបានទេ (ហេព្រើរ ១២:២២-២៣)។[២៦] ព្រះជាម្ចាស់ បានបើកសំដែងអង្គទ្រង់ដោយការបើកសំដែងវត្តមានដ៏រស់របស់ទ្រង់នៅក្នុងព្រះវិហារដ៏ពិត។ ការថ្វាយបង្គំពិតប្រាកដមានព្រះវិហារថ្មីមួយ គឺព្រះយេស៊ូវជំនួសព្រះវិហារនៅលើផែនដី។ ឥឡូវនេះរាស្ត្ររបស់ព្រះអាចទទួលបានជីវិតអស់កល្បជានិច្ចនិងព្រះពរជាបរិបូរណ៍នៃការបង្កបង្កើតថ្មីដែលមានតាមរយៈសិទ្ធិរស់នៅលើទឹកដីនិងមរតកជាអចិន្ត្រៃយ៍មួយ។

ទីបំផុត ព្រះដ៏បរិសុទ្ធទទួលស្គាល់ពួកជំនុំ គឺមិនបដិសេធពួកជំនុំនោះទេ។ រោងឧបោសថគឺជាកន្លែងស្ថានសួគ៌និងផែនដីជួបគ្នាដោយមានសិរីល្អរបស់ព្រះគង់លើបល្ល័ង្កដែលមើលមិនឃើញនៅលើទីសន្តោសប្រោសរបស់ហិបសម្ព័ន្ធមេត្រីខាងក្រោយវាំងននការពារទីបរិសុទ្ធបំផុត។ មនុស្សនឹងមានការជួបព្រះដែលប្រសើរជាងនៅពេលព្រះវិហារពិតប្រាកដគង់ក្នុងចំណោមយើង (កូល៉ុស ២:១៧)។ នៅពេលព្រះយេស៊ូវដែលជាព្រះវិហារដ៏ពិតប្រាកដត្រូវបានគេឆ្កាង នោះរូបកាយរបស់ទ្រង់ត្រូវបាក់បែកនិងលោហិតបានស្រក់ដើម្បីសងថ្លៃអំពើបាបរបស់យើង ហើយគឺ "គ្រានោះវាំងននក្នុងព្រះវិហារក៏រហែកជាពីរភាគ ចាប់តាំងពីលើចុះដល់ក្រោម" (ម៉ាថាយ ២៧:៥១)។

ព្រះយេស៊ូវដែលមានអំណរក្នុងទំនាក់ទំនងជាមួយព្រះវរបិតានិងព្រះវិញ្ញាណបរិសុទ្ធបានយាងចូលប្រទេសឆ្ងាយមួយដើម្បីស្វែងរកអ្នកក្រៅដែលតូចទាបនិងបាត់បង់ ដោយអង្គទ្រង់បានត្រឡប់ជាអ្នកក្រៅដែលគេបដិសេធ បោះបង់ចោលកៀបសង្កត់និងត្រូវគេមើលងាយជំនួសសេចក្ដីទុច្ចរិតរបស់ពួកជំនុំ (ប្រៀបធៀប ហេព្រើរ ១៣:១១-១២)។ វាំងននការពារត្រូវរហែក ដាវភ្លើងរបស់ទេវតាបានបញ្ឈប់យញ្ញបូជាដើម្បីឲ្យយើងជាពួកជំនុំអាចចូលទៅចំពោះវត្តមានរបស់ព្រះដ៏បរិសុទ្ធរបស់យើងជារៀងដរាបទៅ។ និក្ខមនំ ៤០:៣៣ និយាយថា "ដូច្នេះម៉ូសេបានធ្វើការទាំងនោះរួចជាស្រេច" (ប្រៀបធៀប លោកុប្បត្តិ ២:២ "ការដែលព្រះទ្រង់ធ្វើ នោះបានហើយជាស្រេច") ដែលជាស្រមោលនៃព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូវនិងការបំពេញសម្រេចសេចក្ដីប្រោសលោះយ៉ាងឥតខ្ចោះរបស់ទ្រង់ "ការស្រេចហើយ" (យ៉ូហាន ១៩:៣០)។ ពួកជំនុំត្រូវបានរំដោះឲ្យរួចពីចំណងដោយទទេដើម្បីរីករាយជាមួយព្រះរបស់យើងដែលជាព្រះវិញ្ញាណ ដើម្បីឲ្យយើងថ្វាយបង្គំទ្រង់ដោយវិញ្ញាណនិងក្នុងព្រះវិហារដ៏ពិត។

ការបំពេញសម្រេចការគ្រប់គ្រងរបស់ព្រះ។ ព្រះយេស៊ូវមិនគ្រាន់តែជារាស្ត្រពិតប្រាកដរបស់ព្រះនិងជាវត្តមានរបស់ព្រះប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ជាអំណាចធំបំផុតនៃព្រះផងដែរ។ ជាឧទាហរណ៍ ទ្រង់បញ្ចេញសកម្មភាពប្រទានទឹកដែលផ្ដល់ជីវិតដែលនេះគឺជាសកម្មភាពដែលមានតែព្រះអាទិករប្រកបដោយអធិបតីភាពទេដែលមានអំណាចប្រទានជីវិតបាន (សូមមើល អេសាយ ៤៤:៣) (យ៉ូហាន ៤:១៣-១៤ សូមមើលផងដែរ ៤:១០)។ និទានកថាក្នុងព្រះគម្ពីរសញ្ញាចាស់ស្ដីអំពីទាំងការបង្កបង្កើតនិងសេចក្ដីសង្គ្រោះពណ៌នាអំពីព្រះថាមានតែទ្រង់ប៉ុណ្ណោះដែលមានអំណាចប្រទានជីវិត (លោកុប្បត្តិ ១:១១-១២, ២០-៣១, ២:៧ យ៉ូប ៣៣:៤ អេសាយ ៤២:៥ អេសេគាល ៣៦:២៦)។ សកម្មភាពប្រទានជីវិតរបស់ព្រះជាម្ចាស់មកពីអត្តសញ្ញាណផ្ទាល់របស់ទ្រង់ ហើយវាធ្វើឲ្យទ្រង់មានលក្ខណៈពិសេសដាច់ដោយឡែក។

ព្រះយេស៊ូវបំពេញតួនាទីរបស់ព្រះជាម្ចាស់ទាំងអស់។ និយាយតាមពាក្យផ្សេង ព្រះយេស៊ូវចូលរួមក្នុងសកម្មភាពនៃការបង្កបង្កើតនិងការបង្កបង្កើតថ្មីរបស់ព្រះ។[២៧] ព្រះយេស៊ូវបានមានបន្ទូលឆ្លើយនឹងស្ត្រីក្នុងគម្ពីរយ៉ូហាន ៤ ថា "តែអ្នកណាផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឲ្យនឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច" (៤:១៤)។ ព្រះយេស៊ូវប្រទានជីវិត ទ្រង់ប្រទានសិទ្ធិឲ្យត្រឡប់ជាកូនរបស់ព្រះ។ មើល គម្ពីរយ៉ូហាន ១:១២ "ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់នោះទ្រង់បានប្រទានអំណាចឱ្យបានត្រឡប់ជាកូនព្រះ" ហើយ ៥:២១ "ដ្បិត ដែលព្រះវរបិតាទ្រង់ប្រោសមនុស្សស្លាប់ឱ្យមានជីវិតរស់ឡើងវិញយ៉ាងណា នោះព្រះរាជបុត្រានឹងប្រោសដល់អ្នកណាដែលទ្រង់សព្វព្រះហឫទ័យ ក៏យ៉ាងដូច្នោះដែរ"។

## នគរព្រះចាក់ពុម្ព/ បណ្តាលឲ្យអត្តសញ្ញាណរបស់គ្រីស្ទបរិស័ទមានរូបរាងឡើង

ឯកសារអំពីសេចក្តីជំនឿរបស់យើងថ្លែងថា "អស់អ្នកដែលបានសង្គ្រោះដោយសារព្រះគុណនៃព្រះតាមរយៈការរួបរួមជាមួយនឹងព្រះគ្រីស្ទដោយសេចក្តីជំនឿហើយតាមរយៈការបង្កើតជាថ្មីដោយសារព្រះវិញ្ញាណបរិសុទ្ធចូលក្នុងនគរព្រះ"។ គ្រីស្ទបរិស័ទនៅក្នុងនគរព្រះ ហើយសេចក្តីពិតនេះមានឥទ្ធិពលលើអត្តសញ្ញាណរបស់យើងជាចាំបាច់។ ព្រះគ្រប់គ្រងលើជីវិតរបស់គ្រីស្ទបរិស័ទក្នុងរបៀបបីផ្សេងៗពីគ្នា ការងាររបស់ព្រះគុណ គុណប្រយោជន៍មកពីព្រះគុណ និងលទ្ធផលមកពីព្រះគុណ។

### ការងារដោយព្រះគុណ

ទីមួយ ព្រះអង្គគ្រប់គ្រងដោយទ្រង់បានប្រោសលោះយើង។ ការប្រោសលោះនេះត្រូវបានសម្រេចដោយព្រះយេស៊ូវគ្រីស្ទ។ ព្រះអង្គបានកែយើងជាថ្មីឡើងវិញ ផ្សះផ្សាជាមួយយើង និងអនុញ្ញាតមនុស្សមានបាបឲ្យចូលក្នុងនគរព្រះ។ មនុស្សដែលតាំងចិត្តផ្តោតលើខ្លួនឯង នោះមិនព្រមចុះចូលនឹងព្រះគុណឡើយ ពីព្រោះពួកគេមិនចង់មានអំណាចណាផ្សេងក្នុងជីវិតជាជាងអំណាចផ្ទាល់ខ្លួនពួកគេនោះឡើយ។ វាគឺជាការតស៊ូដ៏ធំមួយ។ ព្រះគម្ពីរពណ៌នាអំពីស្ថានភាពរបស់មនុស្សជាការរស់នៅក្រោមអំណាចនៃអំពើបាបនិងសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម (អេភេសូរ ២:១-៣)។ នេះជាមូលហេតុដែលយើងត្រូវការសេចក្តីប្រោសលោះចេញពីអំពើបាបដោយការងារសង្គ្រោះរបស់ព្រះដ៏មានសេចក្តីមេត្តាករុណា។ លោកបោកខាំBauckhamថ្លែងថា

> ការជំរុញរបស់អំពើបាបបានចាប់យើងយ៉ាងណែនមិនឲ្យយើងមានសេរីភាពដោយខ្លួនឯង មិនគ្រាន់តែជាការជំរុញឲ្យយើងធ្វើបាបពីខាងក្នុងលក្ខណៈធ្លាក់ចុះរបស់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាកំឡាំងពីខាងក្រៅបុគ្គលម្នាក់ៗផងដែរ ដែលទាក់ទាញដល់បំណងចិត្តទាបបំផុតរបស់មនុស្ស ហើយទាញយកផលប្រយោជន៍ពីទំនោររបស់មនុស្សចំពោះការលោភចង់បាន តណ្ហា និងការចង់បានលើសប្រមាណ។ ការចាប់មនុស្សជាច្រើនគឺជាសម្ព័ន្ធភាពរវាងភាពអាក្រក់បំផុតរបស់កំឡាំងដែលគ្រប់គ្រងសង្គមរបស់យើង ហើយចំនុចអាក្រក់បំផុតនៃខាងក្នុងខ្លួនរបស់ពួកគេផ្ទាល់។[២៨]

ប៉ុលថ្លែងថា ចិត្តរបស់មនុស្សបានធ្លាក់ចុះ ប៉ុន្តែគាត់មិននិយាយថា យើងធ្វើឲ្យចិត្តរបស់យើងរឹងដោយព្រោះការយល់ដឹងរបស់យើងគឹងងឹត ប៉ុន្តែគាត់និយាយថា ការយល់ដឹងរបស់យើងគឹងងឹតដោយសារតែភាពរឹងចចេសនិងសេចក្តីពុករលួយនៃចិត្តរបស់យើង (អេភេសូរ ៤:១៨)។ ព្រះបានបើកសំដែងរាជ្យរបស់ទ្រង់នៅលើផែនដីដើម្បីប្រោសលោះមនុស្សដែលធ្លាក់ចុះ។ អំពើបាបគឺជាការដាក់អ្វីផ្សេងលើសជាងព្រះនៅក្នុងចិត្តរបស់យើងដើម្បីគ្រប់គ្រងការចង់បានសុភមង្គល សារៈសំខាន់ និងអត្តសញ្ញាណរបស់យើង (សូមមើលនិក្ខមនំ ២០:១-២, រ៉ូម ១:២៥)។ អំពើបាបគឺជាបំណងចិត្តរបស់យើងក្នុងការដាក់ខ្លួនឯងជំនួសព្រះ ប៉ុន្តែព្រះបើកសំដែងព្រះគុណរបស់ទ្រង់ដោយព្រះយេស៊ូវជំនួសយើងវិញ។[២៩] ដោយសារព្រះគុណ ទ្រង់បានប្រោសលោះយើងដោយការធួននឹងបាប ហើយទ្រង់បានទទួលទណ្ឌកម្មដែលអំពើបាបរបស់យើងសមនឹងទទួល ហើយទ្រង់បានប្រទានការរាប់ជាសុចរិតនិងទទួលយើងដោយទទេ។

ដោយសារតែកំលាំងរបស់អំពើបាបពីខាងក្នុង ព្រះគម្ពីរផ្តោតលើសារៈសំខាន់នៃជីវិតខាងក្នុងជាជាងជីវិតខាងក្រៅ។ បើសិនជីវិតបុគ្គលរស់នៅខាងឯអ្វីផ្សេងក្រៅពីខាងឯព្រះយេស៊ូវ (ដូចជាវិជ្ជាជីវៈ ឬទំនាក់ទំនង ឬចរិកា ឬជោគជ័យការសិក្សា ឬទំនាក់ទំនងផ្លូវភេទ) នោះអ្វីដែលយើងជ្រើសរើសបម្រើ នឹងបំពានកំទេច និងផ្តាច់ការចំពោះចិត្តរបស់យើងហើយ។

ព្រះអង្គដ៏ជាស្តេចនឹងទទួលអស់អ្នកដែលរស់នៅសម្រាប់ព្រះយេស៊ូវដោយសេចក្តីស្រលាញ់ហើយគេនឹងមានសេរីភាព (កាឡាទី ៥:១)។ ការរស់នៅសម្រាប់អំនួតអាត្មានិយមរបស់មនុស្សនឹងធ្វើឲ្យគេរស់នៅក្រោមបណ្តាសា ពីព្រោះមនុស្សមិនអាចរស់តាមខ្នាតគំរូរបស់ពួកគេទេ ហើយពួកគេពិតជាមិនអាចបំពេញតាមខ្នាតគំរូនៃក្រឹត្យវិន័យបរិសុទ្ធឥតខ្ចោះរបស់ព្រះបានឡើយ។ អត្តសញ្ញាណរបស់ខ្ញុំមិនសំអាងទៅលើខ្ញុំជានរណាទេ តែសំអាងទៅលើខ្ញុំជារបស់អ្នកណាវិញ។ ដូច្នេះ ទាំង

មនុស្សមានសាសនានិងឥតសាសនាកំពុងគេចចេញពីព្រះដែលជាព្រះអង្គសង្គ្រោះនិងព្រះអម្ចាស់ ប៉ុន្តែក្នុងរបៀបខុសៗគ្នា។ មនុស្សទាំងពីរប្រភេទនេះកំពុងតែខិតខំរក្សាការគ្រប់គ្រងជីវិតរបស់ពួកគេដោយការស្វែងរកអ្វីមួយដែលមិនមែនព្រះមកធ្វើជាសេចក្តីសង្គ្រោះរបស់ពួកគេ។[៣០]

ព្រះគម្ពីរផ្តល់ឲ្យយើងនូវរូបភាពល្អមួយអំពីដំណឹងល្អដែលមានចំនុចជាច្រើន។ អ្នកខ្លះបានព្យាយាមធ្វើឲ្យ "ដំណឹងល្អអំពីជីវិតអស់កល្បជានិច្ច" ដែលជាដំណឹងល្អដែលយ៉ូហានបានផ្តោត ប្រកួតប្រឆាំងនឹង "ដំណឹងល្អអំពីនគរ" នៅក្នុងកណ្ឌដំណឹងល្អទាំងបី (ម៉ាថាយ ម៉ាកុស និងលូកា) ប៉ុន្តែអ្នកនិពន្ធកណ្ឌដំណឹងល្អនីមួយៗកំពុងបញ្ជាក់បង្ហាញអំពីទំរង់មួយដែលមិនត្រឹមតែមានប្រយោជន៍សម្រាប់ការផ្តោតរបស់ពួកគាត់ផ្ទាល់នោះទេ ប៉ុន្តែក៏មានប្រយោជន៍សម្រាប់អ្នកអានរបស់ពួកគាត់ផងដែរ។

លើសពីនេះ ទាំងកណ្ឌគម្ពីរយ៉ូហាននិងកណ្ឌដំណឹងល្អទាំងបីធ្វើឲ្យ "ជីវិត" និង "នគរព្រះ" មានទំនាក់ទំនងគ្នា។ នៅពេលព្រះយេស៊ូវឆ្លើយតបចំពោះនីកូដេមក្នុងដំណឹងល្អរបស់យ៉ូហាន ទ្រង់បញ្ចូលគំនិតអំពីការកែជាថ្មីឡើងវិញនិងជីវិតថ្មីជាមួយនគរព្រះដើម្បីពន្យល់ដល់ផារិស៊ីម្នាក់អំពីសេចក្តីពិតផ្សេងៗអំពីជីវិតថ្មីនេះ (យ៉ូហាន ៣:៣, ៥)។

ស្រដៀងគ្នាដែរ ម៉ាកុសកត់ត្រាពេលព្រះយេស៊ូវមានបន្ទូលថា "បើដៃអ្នកនាំឲ្យគេរវាតចិត្ត នោះចូរកាត់វាចោលទៅ ស៊ូឲ្យអ្នកចូលទៅក្នុង*ជីវិត*កំបុតដៃវិញ ជាជាងមានដៃពីរ ហើយធ្លាក់ទៅនរក នៅក្នុងភ្លើងដែលពន្លត់មិនបាន" (ម៉ាកុស ៩:៤៣)។ ម៉្យាងវិញទៀត ខ. ៤៧ ព្រះយេស៊ូវមានបន្ទូលថា "ហើយបើភ្នែកអ្នកនាំឲ្យគេរវាតចិត្ត នោះចូរខ្វេះចោលទៅ ស៊ូឲ្យអ្នកចូលក្នុង*នគរព្រះ*មានភ្នែកតែមួយ ជាជាងមានភ្នែកទាំងពីរ ហើយត្រូវបោះចោលទៅក្នុងភ្លើងនរកវិញ" ។ ដូច្នេះម៉ាកុសប្រើពាក្យ"ជីវិត"សំដៅលើនគរព្រះ។

យ៉ូហានប្រើ "ជីវិត" និង "ជីវិតអស់កល្បជានិច្ច" សំដៅលើនគរព្រះ។ នៅក្នុងការសរសេររបស់យ៉ូហាន ជីវិតអស់កល្បជានិច្ចគឺជាសេចក្តីពិតដូចគ្នានឹងនគរព្រះដែរ។ គាត់ប្រើពាក្យទាំងពីរនេះផ្លាស់ប្តូរគ្នាបានមិនត្រឹមតែដើម្បីសំដៅលើអំណាចរបស់ព្រះអង្គសង្គ្រោះដែលប្រទានជីវិតអស់កល្បជានិច្ចនោះទេ ប៉ុន្តែក៏ដើម្បីសំដៅលើស្តេចមួយអង្គដែលគ្រប់គ្រងចិត្តរបស់មនុស្សផងដែរ។

## គុណប្រយោជន៍មកពីព្រះគុណ

គុណប្រយោជន៍មួយដែលមកពីយើងរួបរួមជាមួយព្រះគ្រីស្ទនិងការទទួលបានជីវិតអស់កល្បជានិច្ចនិងការអត់ទោសអំពើបាបគឺ យើងក្លាយជាប្រជារាស្ត្រថ្មីមួយក្នុងនគរព្រះ (អេភេសូរ ២:១៩ ភីលីព ៣:២០)។ នេះទាក់ទងនឹងបទពិសោធន៍ផ្ទាល់ខ្លួននិងអន្តរកម្មសាធារណៈរបស់គ្រីស្ទបរិស័ទ។ ប៉ុលពណ៌នាអំពីសិទ្ធិនិងកាតព្វកិច្ចផ្សេងៗរបស់ប្រជារាស្ត្រម្នាក់ដែលជាអ្នកចំឡែកនិងអ្នកប្រទេសក្រៅនៅក្នុងទឹកដីផ្សេង។ ពួកគ្រីស្ទបរិស័ទធ្វើឲ្យខ្លួនពួកគេមានទំនាក់ទំនងជាមួយអ្នកដទៃក្នុងរបៀបលើកស្ទួយដំណឹងល្អ ស្វែងរកផលប្រយោជន៍ឲ្យអ្នកដទៃ និងនាំសិរីល្អដល់ព្រះគ្រីស្ទ។ ពួកគេធ្វើបែបនេះដោយសារពួកគេគឺជាសមាជិករបស់សហគមន៍ផ្សេងមួយដែលជានគរព្រះ ហើយមានការរួបរួមជាមួយព្រះអង្គដែលគ្រប់គ្រងលើប្រវត្តិសាស្ត្រ គឺជាព្រះគ្រីស្ទ។

សូម្បីតែនៅពេលពលរដ្ឋរ៉ូមម៉ាំងបានចេញពីក្រុងកំណើតរបស់ខ្លួន ក៏សិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេជាពលរដ្ឋនៅតែដដែលនៅកន្លែងណាក៏ដោយក្នុងចក្រភពរ៉ូមដែលពួកគេធ្វើដំណើរទៅដល់។ ក្នុងរបៀបដូចគ្នា សិទ្ធិនិងការទទួលខុសត្រូវរបស់គ្រីស្ទបរិស័ទនៅក្នុងនគររបស់ស្តេចយេស៊ូវនៅតែមាន ទោះដល់តំបន់ឆ្ងាយបំផុតក្នុងរាជ្យរបស់ទ្រង់ក៏ដោយ។ម្តងទៀត ដូចដែលប៉ុលបានមានសិទ្ធិប្តឹងឧទ្ធរណ៍ដល់អធិរាជរ៉ូមម៉ាំង នោះរាស្ត្រក្នុងនគរព្រះអាចប្តឹងឧទ្ធរណ៍ដល់អំណាចរបស់ស្តេចយេស៊ូវផងដែរ។

ទោះយ៉ាងណា គ្រីស្ទបរិស័ទគួរតែមានការលើកទឹកចិត្តក្នុងការដឹងថា ព្រះយេស៊ូវគឺជាអធិរាជខុសពីគេ គឺទ្រង់តែងតែឆ្លើយតបដោយការចាប់អារម្មណ៍ចំពោះរឿងក្តីនិងកង្វល់របស់រាស្ត្រទ្រង់។ ដោយព្រោះដំណឹងល្អបានបញ្ជាក់អះអាងអំពីការ

ប្រឈមតាមផ្លូវច្បាប់និងឋានៈអចិន្ត្រៃយ៍របស់គ្រីស្ទបរិស័ទ។នគ្រីស្ទបរិស័ទអាចដឹងអំពីសេចក្តីពិតដែលថា មិនមានគ្រីស្ទបរិស័ទខ្លះដែលជារាស្ត្រក្នុងនគរព្រះមានតំលៃលើសជាងគ្រីស្ទបរិស័ទផ្សេងទៀតនោះទេ គឺគ្រីស្ទបរិស័ទគ្រប់រូបគឺជាប្រជារាស្ត្រដែលមានភាពស្មើៗគ្នា។

និយាយតាមរបៀបផ្សេង អ្នកជាពលរដ្ឋម្នាក់ឬក៏មិនមែន អ្នកជាកូនព្រះម្នាក់ឬក៏មិនមែន។ សេចក្តីពិតនេះនឹងបញ្ឈប់យើងពីការជឿលើទស្សនៈខុសឆ្គងដែលថា ការប្រព្រឹត្តរបស់យើងកំណត់ឋានៈរបស់យើងម្នាក់ៗជាពលរដ្ឋក្នុងនគរព្រះ។ និយាយតាមរបៀបមួយផ្សេងទៀត អ្នកមិនក្លាយជាពលរដ្ឋដែលមានឋានៈទីពីរក្នុងនគរព្រះនៅពេលអ្នកស្តាប់បង្គាប់ព្រះបានតិច ហើយក្លាយជាពលរដ្ឋដែលមានឋានៈទីមួយនៅពេលអ្នកស្តាប់បង្គាប់ព្រះបានច្រើនជាងនោះឡើយ។

ហើយតើអ្វីជាលក្ខណៈវិនិច្ឆ័យដែលធ្វើឲ្យបុគ្គលម្នាក់ក្លាយជាពលរដ្ឋម្នាក់ក្នុងប្រទេសជាតិមួយបាន? វាមិនជាសញ្ជាតិ ភាសា ឬប្រវត្តិវប្បធម៌នោះទេ។ ការក្លាយជាពលរដ្ឋម្នាក់អាស្រ័យទៅលើរដ្ឋាភិបាលឬស្តេចទទួលស្គាល់គេជាពលរដ្ឋ។ តើអ្វីគឺជាលក្ខណៈវិនិច្ឆ័យសម្រាប់មនុស្សម្នាក់ធ្វើជាគ្រីស្ទបរិស័ទ? វាជាសេចក្តីពិតដែលមនុស្សបានទទួលសិទ្ធិធ្វើជាពលរដ្ឋនៃនគរព្រះមិនដោយសារកត្តាសីលធម៌ ជាតិសាសន៍ វប្បធម៌ ឬសង្គមនោះទេ ប៉ុន្តែដោយសារព្រះគុណរបស់ស្តេចយេស៊ូវវិញ។ ពីមុនគាត់ជាអ្នកដទៃ (អេភេសូរ ២:១៩) ឥឡូវគាត់គឺជាពលរដ្ឋដែលមានសិទ្ធិនិងឯកសិទ្ធិពេញលេញនៅក្នុងសហគមន៍ថ្មីមួយ។

## លទ្ធផលមកពីព្រះគុណ

ក្នុងនាមជារាស្ត្រស្ថានសួគ៌ យើងមិនគ្រាន់តែមានសិទ្ធិនិងឯកសិទ្ធិប៉ុណ្ណោះទេ លើសពីនោះយើងមានទំនួលខុសត្រូវក្នុងការធ្វើជាអ្នកតំណាងរបស់ស្តេចនៃនគរនេះឲ្យបានល្អ។ ក្នុងនាម "ជាជាតិតែមួយនឹងពួកបរិសុទ្ធ" (អេភេសូរ ២:១៩) រាស្ត្ររបស់ព្រះគឺជាសហគមន៍មួយដែលមានជីវិតនិងសីលធម៌ខុសពីវប្បធម៌ដែលយើងរស់នៅក្នុង។ រាស្ត្ររបស់ព្រះមានភាសាខាងវិញ្ញាណនិងបម្រើព្រះជាមួយគ្នា។ ពួកគេមិនគ្រាន់តែមានកាតព្វកិច្ចនិងទំនួលខុសត្រូវរួមប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះពួកគេមានគោលដៅរួមមួយ និងរីករាយក្នុងការថ្វាយសិរីល្អ គោរព និងស្តាប់បង្គាប់ស្តេចពិតប្រាកដតែមួយអង្គ។

ទោះជាយ៉ាងណា ក្រៅពីការលើកតម្កើងព្រះរបស់យើង ក៏ជារឿយៗយើងតែងអបអរសាទរនិងសរសើរដល់ខ្លួនយើងផងដែរ។ ប៉ុន្តែព្រះគណដែលសង្គ្រោះបានដាស់ឲ្យយើងមើលឃើញឫទ្ធានុភាពដែលព្រះយេស៊ូវមាន។ រូបភាពអំពីភាពជាស្តេចរបស់ទ្រង់ក្នុងការចូលក្រុងយេរូសាឡឹម (យ៉ូហាន ១២:១២-១៩) គឺជាការរួមបញ្ចូលឫទ្ធានុភាពនិងភាពឱនលំទោនភាពបរិសុទ្ធនិងការបន្ទាបខ្លួន។ ព្រះយេស៊ូវគឺជាស្តេចផ្ទុយពីស្តេចផ្សេងៗទៀត គឺទ្រង់ជាស្តេចបម្រើដែលបានយាងមកដោយការបន្ទាបខ្លួន។ អ្វីដែលយើងចង់បានគឺជាស្តេចឥតខ្ចោះមួយអង្គ។ យើងចង់បានស្តេចល្អប្រសើរបំផុតដែលក្លាហាននិងទន់ភ្លន់ ក្លាហាននិងឱនលំទោន។

នៅក្នុងដំណឹងល្អយ៉ូហាន នៅពេលលោកយ៉ូហានប្រើពាក្យ "ដំកើងឡើង" ឬ "លើកឡើង" ជារឿយៗគាត់កំពុងសំដៅលើឈើឆ្កាង។ ដូច្នេះ អ្វីដែលយ៉ូហានកំពុងព្យាយាមនិយាយគឺថា បើសិនអ្នកចង់ដឹងអំពីភាពពេញលេញនៃសិរីល្អរបស់ព្រះ នោះអ្នកមិនរកឃើញនៅក្នុងជោគជ័យនៃការអស្ចារ្យនោះទេ ប៉ុន្តែអ្នកអាចរកឃើញនៅឈើឆ្កាងវិញ។ ព្រះយេស៊ូវគ្រីស្ទមានផ្លូវដែលទ្រង់នឹងបង្ហាញយើងគឺថា ទ្រង់គឺជាស្តេចដ៏អស្ចារ្យមួយអង្គដែលបានលះចោលទ្រព្យសម្បត្តិនៅស្ថានសួគ៌ ហើយបានមកក្នុងលោកិយនេះ ត្រឡប់ជាគ្មានអ្វីសោះ ហើយបានធ្វើឲ្យអ្នកដែលក្រក្លាយជាមានវិញ។

មនុស្សបានមានការរំពឹងចង់បានខុសអំពីស្តេចមែស៊ីរបស់ពួកគេ ហើយពួកគេមិនបានសង្ឃឹមទុកជាមុនថា ព្រះមែស៊ីនឹងអភិសេកដោយទ្រង់សុគតនៅលើឈើឆ្កាងនោះទេ។ នៅពេលណាយើងគិតអំពីភាពជាស្តេចរបស់ព្រះយេស៊ូវដែលផ្ទុយពីគេ ទ្រង់មានឫទ្ធានុភាពនិងភាពឱលំទោន បរិសុទ្ធនិងបន្ទាបខ្លួន នោះយើងមានបំណងចិត្តចង់បានភាពស្មោះត្រង់ដូចគ្នាដែលធ្វើឲ្យចិត្តរបស់យើងត្រឡប់ជាស្លូតនិងមានសេចក្តីមេត្តាករុណាដូចជាចៀម និងក្លាហានដូចជាសឹង្ហ។ លោក ខេលី Keller សង្ខេបឧត្តមភាពរបស់ព្រះនេះបានយ៉ាងល្អថា

វាជាប្រតិមតិចំពោះលោកិយ ប៉ុន្តែគ្រីស្ទបរិស័ទឃើញថាព្រះយេស៊ូវគឺជាស្តេចពិតប្រាកដ។ ព្រះយេស៊ូវមានអំណាចគ្មានព្រំដែនប៉ុន្តែទ្រង់បានមកយករូបភាពជាបាវបម្រើវិញព្រមទាំងប្រសូតមកមានរូបជាមនុស្សផងហើយបន្ទាបព្រះអង្គទ្រង់ទាំងចុះចូលស្តាប់បង្គាប់រហូតដល់ទីមរណៈគឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង។ ទ្រង់មានយុត្តិធម៌តែមានសេចក្តីមេត្តាករុណា ទ្រង់នៅឯស្ថានដ៏ខ្ពស់ ក៏នៅជាមួយយើងដែលទន់ទាបផងដែរ។ព្រះគ្រីស្ទមានអំណាចព្រះចេស្តា ប៉ុន្តែទ្រង់គ្រប់គ្រងចិត្តយ៉ាងសុចរិត។ យើងមានការទាក់ទាញជ្រាលជ្រៅ។ ទ្រង់គឺជាម្ចាស់និងស្តេចដែលយើងទាំងអស់គ្នាទន្ទឹងចង់បាន។ ឫទ្ធានុភាពគឺកាន់តែមានឫទ្ធានុភាពពីព្រោះទ្រង់មានភាពទន់ភ្លន់ ភាពទន់ភ្លន់កាន់តែទន់ភ្លន់ពីព្រោះទ្រង់មានឫទ្ធានុភាព។ បើសិនអ្នកមកជួបមុខផ្ទាល់ជាមួយស្តេចសុភាពដែលយាងមកដោយជិះសេះនោះអ្នកនឹងក្លាយជាស្តេចសុភាពមួយអង្គ។ អ្នកនឹងត្រឡប់ជាក្លាហានតែកាន់តែបន្ទាបខ្លួន។ ប៉ុន្តែយើងត្រឡប់ជាក្លាហានតែកាន់តែបន្ទាបខ្លួនលុះត្រាតែយើងយល់ថាយើងបានសង្គ្រោះមិនមែនតាមរយៈកម្លាំងរបស់យើងប៉ុន្តែតាមរយៈភាពខ្សោយវិញ យើងមិនបានសង្គ្រោះតាមរយៈសីលធម៌របស់យើងប៉ុន្តែតាមរយៈព្រះគុណរបស់ព្រះវិញ។[៣១]

## *នគរព្រះចាក់ពុម្ព/បណ្តាលឲ្យសហគមន៍មានសណ្ឋានរូបរាងឡើង*

មនុស្ស និង ស្ថាប័ន ទាំងអស់ចាប់អារម្មណ៍លើការផ្លាស់ប្តូរ កែជាថ្មីឡើងឬផ្លាស់ប្រែសង្គមដោយការជះឥទ្ធិពលលើវប្បធម៌តាមរយៈគុណតំលៃគោលរបស់ពួកគេ។ ដូច្នេះ យើងនឹងធ្វើឲ្យមានឥទ្ធិពលលើវប្បធម៌របស់យើង។ នៅពេលមនុស្សនិយាយ នោះគាត់កំពុងនិយាយជាភាសាពីវប្បធម៌មួយហើយគាត់មានទស្សនៈអំពីសីលធម៌និងអំពីអ្វីដែលគាត់ជឿថា "ពិត" "ល្អ" និង "ស្អាត" ហើយវប្បធម៌មានឥទ្ធិពលនឹងទស្សនៈរបស់គាត់។ គ្មានអ្នកណាគិតថា គាត់មិនទទួលឥទ្ធិពលពីសង្គមនោះទេ។

ដើម្បីឆ្លើយនឹងសំនួរ "រដ្ឋាភិបាលទទួលខុសត្រូវចំពោះការអប់រំ អ្នកក្រីក្រ យុត្តិធម៌ សិល្បៈ...ល តើពួកជំនុំត្រូវចូលរួមទទួលខុសត្រូវអំពីរឿងទាំងនេះដែរឬទេ?" នោះយើងត្រូវការគិតពិចារណាដូចតទៅនេះ។ ពួកជំនុំគ្មានអំណាចតាមផ្លូវច្បាប់ណានៅក្នុងក្រុងឬរដ្ឋនោះទេ ប៉ុន្តែនោះមិនន័យថា ពួកជំនុំគួរតែនៅលើផ្ទៃខាងក្រៅ(ហើយមិនចូលរួម)នោះដែរ។ពួកជំនុំពិតជាមានទំនួលខុសត្រូវធ្វើសកម្មភាពដោយសេចក្តីមេត្តាករុណានិងធ្វើអន្តរកម្មជាមួយសហគមន៍របស់យើងដោយសកម្មភាពយុត្តិធម៌ (សូមមើលយ៉ាកុប ១:២៧)។[៣២]

ប៉ុលសរសេរក្នុងកាឡាទី ៦:១០ ថា "កាលណាយើងមានឱកាស នោះត្រូវធ្វើល្អដល់មនុស្សទាំងអស់ ហើយគឺដល់ពួកអ្នកជឿជាដើម"។[៣៣] យ៉ាកុបនិយាយថា សាសនាពិតគឺថា "ឲ្យទៅសួរពួកកំព្រា និងពួកមេម៉ាយ ក្នុងការដែលគេមានសេចក្តីវេទនា ហើយឲ្យរក្សាខ្លួនមិនឲ្យប្រឡាក់ដោយលោកិយនេះឡើយ" (១:២៧)។ និយាយក្នុងពាក្យផ្សេង វាជាទំនួលខុសត្រូវរបស់ពួកជំនុំក្នុងការប្រព្រឹត្តទាំងសេចក្តីមេត្តាករុណាជាសាធារណៈនិងមានជីវិតផ្ទាល់ខ្លួនដែលបរិសុទ្ធ។ ជាឧទាហរណ៍ ទោះបើប្រព័ន្ធសាលាដែលមានកម្រិតទាបមិនមែនជាទំនួលខុសត្រូវរបស់ពួកជំនុំក៏ដោយ ក៏ពួកគ្រីស្ទបរិស័ទអាចប្រព្រឹត្តល្អដោយការជួយផ្តល់ការបង្រៀនក្រៅម៉ោងដល់សាលានៅក្នុងតំបន់បានដែរ។

ពួកគ្រីស្ទបរិស័ទគួរតែអភិវឌ្ឍនមិត្តភាពជាមួយមនុស្សនៅក្នុងសហគមន៍របស់ខ្លួន។ យើងអាចចាប់ដៃគូជាមួយក្រុមអង្គការដែលពាក់ព័ន្ធក្នុងសកម្មភាពដែលមានសេចក្តីមេត្តាករុណានិងសប្បុរសផងដែរ។ ដែលធ្វើការនេះមិនមានន័យថា យើងបានបោះបង់ចោលការអធិប្បាយដំណឹងល្អគឺជាសកម្មភាពសំខាន់បំផុតនោះទេ។តែលទ្ធផលរបស់ដំណឹងល្អគឺថា មនុស្សត្រូវបានផ្លាស់ប្រែដើម្បីយើងចាប់ផ្តើមស្រលាញ់អ្នកជិតខាងរបស់យើងបើទោះជាពីមុនយើងបានធ្លាប់តែស្រលាញ់ខ្លួនឯងប៉ុណ្ណោះក៏ដោយ។

> គំរូនេះផ្ទុយពីគំនិតនិងការអនុវត្តរបស់លោកិយយ៉ាងខ្លាំង ដែលវាបង្កើតនូវ “នគរខុសគ្នា”មួយ “ទីក្រុងខុសគ្នា” មួយ (ម៉ាថាយ ៥:១៤-១៦) ដែលមានភាពផ្ទុយគ្នានឹងគុណតំលៃរបស់លោកិយទាក់ទងនឹងអំណាច ឋានៈ និងទ្រព្យសម្បត្តិ។ ដំណឹងល្អផ្លាស់ប្តូរកន្លែងរបស់អ្នកទន់ខ្សោយនិងអ្នកខ្លាំង “អ្នកក្រៅ” និង “អ្នកក្នុង”។ វាគឺជាគុណប្រយោជន៍ក្នុងការមើលឃើញភាពកម្សោយរបស់យើង បើយើងមានឋានៈខ្ពស់ឬជាអ្នកធំ នោះគ្រោះថ្នាក់សម្រាប់ជីវិតខាងព្រលឹងវិញ្ញាណរបស់យើង។ នៅពេលយើងយល់ថា យើងអាចបានសង្គ្រោះដោយសារព្រះគុណតាមរយៈព្រះគ្រីស្ទ នោះយើងឈប់ស្វែងរកសេចក្តីសង្គ្រោះ តាមរយៈអំណាច ឋានៈ និងសមិទ្ធិផល។ ទស្សនៈថ្មីនេះបោះចោលឥទ្ធិពលរបស់អំណាច ឋានៈ និងសមិទ្ធិផលនៅក្នុងជីវិតរបស់យើង។ ដូច្នេះ ព្រះគុណរបស់ព្រះដែលយើងទទួលបានពីឈើឆ្កាង រំដោះយើងចេញពីចំណងអំណាចនៃទ្រព្យសម្បត្តិនិងឋានៈរបស់លោកិយនៅក្នុងជីវិតរបស់យើង។ យើងចាប់ផ្តើមរស់នៅជាជីវិតថ្មីដែលមិនផ្តល់តំលៃខ្ពស់ដល់របស់ទាំងនេះទេ។[៣៤]

មនុស្សខ្លះរស់នៅក្នុងទីក្រុង ហើយសេចក្តីត្រូវការទាំងអស់របស់ពួកគេត្រូវបានបំពេញសម្រេចនៅក្នុងទីក្រុង។ ពួកគេទទួលបានលិខិតសំគាល់ខ្លួន ឋានៈ ការអប់រំ និងការហ្វឹកហ្វឺន។ អ្នកផ្សេងទៀតស្ទើរតែត្រូវវិនាសដោយសារទីក្រុងទៅហើយ។ ប៉ុន្តែពួកគ្រីស្ទបរិស័ទចង់រស់នៅខុសពីវប្បធម៌ដើម្បីបង្កើតសហគមន៍ថ្មីខុសគ្នានៃនគរព្រះ។ ពួកគេចូលរួមក្នុងវត្តមានរបស់ព្រះនិងការគ្រប់គ្រងរបស់ព្រះក្នុងចំណោមប្រជារាស្ត្រដែលទ្រង់បានអះអាងថាជារបស់ទ្រង់ផ្ទាល់ ដែលទ្រង់ផ្លាស់ប្រែពួកគេឲ្យទៅជាសហគមន៍បរិសុទ្ធខុសពីគេ ដែលទន្ទឹងរង់ចាំអនាគតដែលយើងនឹងមើលឃើញទ្រង់សំដែងបង្ហាញអំណាចរបស់ទ្រង់ពេញទូទាំងពិភពលោក។[៣៥]

ពួកគ្រីស្ទបរិស័ទមិនជឿថា មានរបៀបដែលយើងទាក់ទងនឹងវប្បធម៌តែពីរយ៉ាងប៉ុណ្ណោះទេ(ដូចជាតាមគេ [គឺមានជីវិតនិងទស្សនៈដូចគេ] ឬញែកចេញពីគេហើយមិនពាក់ព័ន្ធនឹងសហគមន៍)។ យេរេមា ២៩ លើកទឹកចិត្តរាស្ត្ររបស់ព្រះកុំឲ្យដើរតាមវប្បធម៌ដទៃ ប៉ុន្តែឲ្យរស់នៅជាមួយនិងពាក់ព័ន្ធក្នុងជីវិត សេដ្ឋកិច្ចនិងវប្បធម៌ក្នុងទីក្រុង។ ហោរាមិនកំពុងហៅឲ្យមនុស្សថ្វាយបង្គំទីក្រុងឬក៏ស្អប់វប្បធម៌នោះដែរ ប៉ុន្តែហៅឲ្យស្រលាញ់ទីក្រុងវិញ។

លោក បារី ស្វត Barry Schwartz និយាយថា មនុស្សមានគោលដៅ ការរំពឹងទុក និងបំណងចិត្តគ្រប់ប្រភេទដើម្បីឈានដល់ឋានៈខ្ពស់ ពីព្រោះយើងប្រៀបធៀបនឹងអ្នកដទៃក្នុងសង្គម ស្វែងរកឱកាសខុសៗគ្នា និងព្យាយាមបំពេញការរំពឹងចង់បានខ្ពស់។[៣៦] គាត់និយាយថា អ្នកមិនអាចដេញតាមគោលដៅរបស់អ្នកផ្ទាល់ ហើយក៏គាំទ្រគោលដៅរបស់អ្នកដទៃផងនោះទេនៅពេលគោលដៅទាំងនេះប្រកួតគ្នា។ វាជាការលំបាកក្នុងការដេញតាមសេចក្តីល្អសម្រាប់មនុស្សទាំងអស់នៅពេលសេចក្តីល្អសម្រាប់មនុស្សទាំងអស់ប្រកួតនឹងផលប្រយោជន៍ផ្ទាល់ខ្លួន។ ទោះយ៉ាងណា

> ដូច្នេះ ដំណឹងល្អបង្កើត “សហគមន៍របស់នគរ” មួយ ជាវប្បធម៌ផ្ទុយមួយ ជាពួកជំនុំ ដែលមានយើងជា “ពួកសង្ឃហ្លួង” បង្ហាញលោកិយថានគរនាពេលអនាគតនឹងដូចជាអ្វី (១ពេត្រុស ២:៩-១០)។ យើង “ធ្វើជាគំរូ”ពីរបៀបដែលព្រះគ្រីស្ទបង្កើតឡើងវិញនូវជីវិតទាំងអស់រួមទាំងការអនុវត្តពាណិជ្ជកម្ម ទំនាក់ទំនងជាតិសាសន៍ ជីវិតក្រុមគ្រួសារ សិល្បៈនិងវប្បធម៌។[៣៧]

សហគមន៍គ្រីស្ទបរិស័ទដែលបម្រើនគរ នឹងមានតុល្យភាពត្រឹមត្រូវរវាង "ការអធិប្បាយដែលមានទេវសាស្ត្រត្រឹមត្រូវការផ្សាយដំណឹងល្អការការពារសេចក្តីជំនឿ និងការរីកចំរើនរបស់ពួកជំនុំ" និងការដាំពួកជំនុំដែលនឹង "ផ្តោតលើការប្រែចិត្តការកែជាថ្មីឡើងវិញផ្ទាល់ខ្លួន និងជីវិតបរិសុទ្ធ" និង "ការពាក់ព័ន្ធល្អជាមួយសង្គម និងពាក់ព័ន្ធជាមួយសិល្បៈ ពាណិជ្ជកម្ម ការអប់រំដ៏ខ្ពង់ខ្ពស់ និងរដ្ឋាភិបាល"។[៣៨]សហគមន៍និងទឹកចិត្តរបស់យើងនឹងបន្តស្តារឡើងវិញនិងបង្កើតឡើងវិញក្រោមការគ្រប់គ្រងរបស់ព្រះគ្រីស្ទដែលជាព្រះសិរសាលើរបស់សព្វសារពើទាំងអស់។

# កំណត់

១. Don Cupitt, "Post-Christianity," in Religion, Modernity, and Postmodernity, Religion and Spirituality in the Modern World, ed. Paul Heelas (Oxford: Blackwell, 1998), 218.

២. Barry Schwartz, The Paradox of Choice: Why More Is Less (New York: HarperCollins, 2004), 2–3.

៣. Richard J. Bauckham, God and the Crisis of Freedom: Biblical and Contemporary Perspectives (Louisville, KY: Westminster, 2002), 50–51.

៤. Ibid., 68.

៥. John Bright, The Kingdom of God (Nashville, TN: Abingdon Press, 1980), 196ff.

៦. The primary definition of both the Hebrew word malkuth and the Greek word basileia describes the rank, authority, and sovereign rule exercised by a king. The kingdom may make reference to the realm, sphere, place, or people, but these are secondary definition entries to that of a sovereign kingly rule (see Pss. 103:19; 145:11, 13; Dan. 2:37).

៧. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤)។

៨. The Gospel Coalition Confessional Statement.

៩. Graeme Goldsworthy, "The Kingdom of God and the Old Testament," http://www.pre-senttruthmag.com/archive/XXII/22-4.htm.

១០. Meredith G. Kline, Kingdom Prologue (Eugene, OR: Wipf & Stock, 2006), 12.

១១. Richard Pratt, "What Is the Kingdom of God?" http://www.thirdmill.org/files/eng-lish/html/th/TH.h.Pratt.kingdom.of.god.html.

១២. Goldsworthy, "Kingdom of God and the Old Testament."

១៣. George R. Beasley-Murray, Jesus and the Kingdom of God (Grand Rapids, MI: Eerdmans, 1988), 19.

១៤. Pratt, "What Is the Kingdom of God?"

១៥. Ibid.

១៦. Beasley-Murray, Jesus and the Kingdom of God, 20.

១៧. John Piper, "Book Review of The Kingdom of God by John Bright," http://www.desir-inggod.org/ResourceLibrary/Articles/ByTopic/30/2687_Book_Review_of_The_Kingdom_of_God_by_John_Bright/.

១៨. George E. Ladd, The Gospel of the Kingdom (Grand Rapids, MI: Eerdmans, 1959), 15.

១៩. Tim Keller, "Preaching the Gospel," PT 123 Gospel Communication (Spring 2003): 58–59.

២០. Richard J. Bauckham, Jesus and the God of Israel: God Crucified and Other Studies on the New Testament's Christology of Divine Identity (Grand Rapids, MI: Eerdmans, 2008), 35.

២១. Piper, "Book Review."

២២. Craig Koester, "The Dwelling of God: The Tabernacle in the Old Testament, Intertestamental Jewish Literature, and the New Testament," CBQMS, 22 (1989): 102.

๒๓. Ibid., 102. John 1:51 ("You shall see heaven open, and the angels of God ascending and descending on the Son of Man").

๒๔. Herman Ridderbos, The Gospel according to John (Grand Rapids, MI: Eerdmans, 1997), 51.

๒๕. D. A. Carson, The Gospel according to John (Grand Rapids, MI: Eerdmans, 1991), 182.

๒๖. Piper, "Book Review."

๒๗. Richard J. Bauckham, God Crucified: Monotheism and Christology in the New Testament, Didsbury Lectures, 1996 (Carlisle: Paternoster, 1998), viii, 35.

๒๘. Bauckham, God and the Crisis of Freedom, 17.

๒๙. John Stott, The Cross of Christ (Downers Grove, IL: InterVarsity, 1986), 160.

๓๐. Tim Keller, "A Gospel for the More Secular," http://redeemer.com/resources, and especially his Counterfeit Gods: The Empty Promises of Money, Sex, and Power, and the Only Hope That Matters (New York: Dutton, 2009).

๓๑. Tim Keller, John 12 sermon, www.redeemer.com/sermons.

๓๒. Confessional Statement: "Good works constitute indispensable evidence of saving grace . . . we are to love our neighbors as ourselves, doing good to all, especially to those who belong to the household of God. It therefore inevitably establishes a new community of human life together under God."

๓๓. Ibid.: "We are to love our neighbors as ourselves, doing good to all, especially to those who belong to the household of God."

๓๔. Tim Keller, "Preaching the Gospel," 33–34.

๓๕. The Gospel Coalition Theological Vision for Ministry.

๓๖. Schwartz, Paradox of Choice, 215–17.

๓๗. Timothy Keller, "Preaching in a Postmodern City," (unpublished version), 21.

๓๘. Ibid.